


សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស

លីកាដូ

LICADHO

Cambodian League for the
Promotion and Defense of
Human Rights


# កុមារភាព នៅក្នុងពន្ធនាគារ៖

## ការចម្រើនវ័យនៅក្នុងពន្ធនាគារកម្ពុជា: រឿងរ៉ាវរបស់ សុខ គុន


របាយការណ៍សង្ខេប
ចេញផ្សាយ ខែតុលា ឆ្នាំ២០១៣

# កុមារភាព នៅក្នុងពន្ធនាគារ៖

## ការចម្រើនវ័យនៅក្នុងពន្ធនាគារកម្ពុជាៈ រឿងរ៉ាវរបស់

## សុខ គុន

របាយការណ៍ចេញខែតុលា ឆ្នាំ២០១៣

**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល។ លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង១២ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តិ ដោយអាជ្ញាធរ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារៈ**

បុគ្គលិកលីកាដូ ធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយអាជ្ញាធរ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ចៈ**

ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារៈ**

អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំ ទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់ៈ**

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្តាញនានាៈ**

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើយុទ្ធនាការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិៈ**

អ្នកហ្វឹកហ្វឺន និងអ្នកទាក់ទាញមតិគាំទ្រ ធ្វើការអប់រំដល់ក្រុមគោលដៅជាក់លាក់មួយចំនួន បណ្តាញគាំទ្រកិច្ចការពារសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន និងធ្វើការតស៊ូមតិសម្រាប់ការផ្លាស់ប្តូរសង្គម និងច្បាប់ ជាមួយស្ត្រី យុវវ័យ និងកុមារ។

**ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍ៈ**

ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេត ដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយ-ការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារៈ (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែលៈ contact@licadho-cambodia.org
គេហទំព័រៈ www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


សេចក្តីផ្តើម ទំព័រ១

អនុសាសន៍ទាំងឡាយ ទំព័រ១១

សារតារ ទំព័រ២

កុមារភាពនៅក្នុងពន្ធនាគារ ទំព័រ៤

វិធីសាស្ត្រសិក្សាស្រាវជ្រាវ ទំព័រ៤

សារតារគ្រួសារ ទំព័រ៤

ជីវប្រវត្តិរបស់ សុខ គុន ទំព័រ៤

ស្ថានភាពមន្ទីរឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី២ ទំព័រ៥

ស្លាកស្នាមជីវិតនៅក្នុងពន្ធនាគារ ទំព័រ៦

ការអប់រំ និងទំនាក់ទំនងមិត្តភក្តិ ទំព័រ៧

ម្តាយ និងចំណងទាក់ទងជាមួយកូន ទំព័រ៧

ផ្ទះកុមារ៖ ការសម្លឹងមើលទៅអនាគត ទំព័រ៨

សេចក្តីសន្និដ្ឋាន ទំព័រ៩




គម្របមុខ៖ ក្មេងស្រីដែលកំពុងរស់នៅក្នុងពន្ធនាគារជាមួយម្តាយ ក្រឡេកមើលមកក្រៅតាមរបងសំណាញ់ដែកនៅពន្ធនាគារនៃ មណ្ឌលអប់រំកែប្រែទី២ នៅរាជធានីភ្នំពេញ




ក្មេងនៅក្នុងពន្ធនាគារត្រូវបានគេមើលឃើញ នៅពេលពិធីអបអរសាទរទីវាសិទ្ធិកុមារអន្តរជាតិ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១១ នៅមណ្ឌលអប់រំកែប្រែទី២

# សេចក្ដីផ្ដើម

នៅប្រទេសកម្ពុជាបច្ចុប្បន្នមានក្មេងៗជាច្រើន កំពុងរស់នៅក្នុងពន្ធនាគារជាមួយម្ដាយ[៩] របស់អ្នកទាំងនោះ ដោយសារតែមានការយល់ដឹងតិចតួចនៅឡើយ ក្នុងចំណោមអាជ្ញាធរ និងសង្គម ជាទូទៅអំពីផលប៉ះពាល់រយៈពេលវែង និងរយៈពេលខ្លីពីជីវិតក្នុងពន្ធនាគារទៅលើកុមារ។ ក្នុងបរិបទនេះ មិនមែនមានតែប្រទេសកម្ពុជាទេ ដែលរហូតមកទល់បច្ចុប្បន្ននេះ មានការសិក្សាស្រាវ ជ្រាវមួយចំនួនប៉ុណ្ណោះអំពីផលប៉ះពាល់ទៅលើកុមារ ដែលបានចំណាយពេលកុមារភាពរបស់អ្នកទាំងនោះ ជាច្រើនឆ្នាំរស់នៅក្នុងពន្ធនាគារ។

ជនជាប់ឃុំក្នុងពន្ធនាគារ គឺស្ថិតក្នុងចំណោមក្រុមមនុស្សដែលងាយរងគ្រោះបំផុតនៅក្នុងសង្គមណាក៏ដោយ ហើយប្រទេសកម្ពុជាក៏មិនខុសគ្នាដែរ។ អ្នកទាំងនោះ ត្រូវកាត់ផ្ដាច់ទំនាក់ទំនងពីសង្គមទាំងផ្លូវកាយ និងផ្លូវចិត្ត។ ជាពិសេសការកាត់ផ្ដាច់ទំនាក់ទំនងនេះ កំពុងធ្វើឲ្យមានភាពទ្រុឌទ្រោមដល់កុមារ ដែលមិនមែនជាអ្នកជាប់ទោស (មិនមែនជាទណ្ឌិតទេ) ប៉ុន្តែជាញឹកញាប់ត្រូវបានគេចាត់ទុកដូចជាអ្នកទោសដែរ។ ធាតុពិតនៃពន្ធនាគារនៅប្រទេសកម្ពុជា គឺមានលក្ខណៈធ្ងន់ធ្ងរសម្រាប់បុគ្គលគ្រប់រូប ប៉ុន្តែលក្ខណៈធ្ងន់ធ្ងរនេះអាចបង្កភាពទ្រុឌទ្រោមយ៉ាងខ្លាំងដល់កុមារផងដែរ។

ទោះជាអ្នកទាំងនោះនៅតែរស់នៅជិតម្ដាយ ហើយអាចទទួលផលប្រយោជន៍ពីចំណងទំនាក់ទំនងរវាងកូន និងម្ដាយក្នុងពេលកុមារភាពរបស់ពួកគេជាច្រើនឆ្នាំក៏ដោយ ក៏កុមារដែលស្នាក់នៅក្នុងពន្ធនាគារនៅកម្ពុជា ត្រូវបានគេដកហូតកត្តាជាមូលដ្ឋាននៃកុមារភាពរបស់អ្នកទាំងនោះផងដែរ ដូចជាសហគមន៍ មិត្តភក្តិ និងឱកាសរៀនសូត្រតាមរយៈបទពិសោធន៍ ដោយផ្ទាល់។

នេះជាករណីសិក្សាលើកដំបូង ក្នុងករណីសិក្សាមួយឈុតដែលអង្គការលីកាដូ បានចេញផ្សាយ ដោយធ្វើការវាយតម្លៃលើផលប៉ះពាល់ទៅលើកុមារ ដែលកំពុងចំរើនវ័យនៅក្នុងពន្ធនាគារកម្ពុជា។ ករណីសិក្សាមួយឈុតនេះ មានគោលដៅផ្ដល់ការយល់កាន់តែ

**កុមាររស់នៅក្នុងពន្ធនាគារនៅប្រទេសកម្ពុជាជារឿយៗត្រូវបានសង្គមបំភ្លេចចោល។ កាន់តែធ្ងន់ធ្ងរជាងមុន កុមារជារឿយៗក៏មិនត្រូវបានយកចិត្តទុកដាក់ដោយអាជ្ញាធរ ដែលទទួលខុសត្រូវចំពោះអ្នកទាំងនោះដែរ។**

លំអិតខ្លាំងអំពីផលវិបាកខាងផ្លូវកាយ និងផ្លូវចិត្តសម្រាប់កុមារ ដែលបានរស់នៅក្នុងពន្ធនាគារជាមួយម្ដាយរបស់ទាំងនោះ។

[៩] នៅប្រទេសកម្ពុជាបច្ចុប្បន្ន មិនមានក្មេងរស់នៅក្នុងពន្ធនាគារជាមួយឪពុក ឬអ្នកថែទាំបឋមដ៏ទៃទៀតឡើយ។

ជាមួយរបាយការណ៍ទាំងនេះ អង្គការលីកាដូ មានគោលដៅបង្កើតការយល់ដឹងទូលំទូលាយមួយ ជាពិសេសក្នុងចំណោមអាជ្ញាធរពន្ធនាគារ និងអាជ្ញាធរតុលាការកម្ពុជាអំពីពេលវេលាសមស្រប និងសមហេតុផលក្នុងការអនុញ្ញាតឲ្យកុមារស្នាក់ នៅក្នុងពន្ធនាគារជាមួយម្តាយរបស់អ្នកទាំងនោះ ហើយនឹងការឧបត្ថម្ភពិសេសត្រូវតែដាក់ឲ្យដំណើរការ ដើម្បីបំពេញសេចក្តីត្រូវការពិសេសរបស់ម្តាយ និងកុមារ។ ដោយផ្តោតយកចិត្តទុកដាក់លើករណីសិក្សាជាលក្ខណៈបុគ្គល អង្គការលីកាដូ មានគោលដៅផ្តល់នូវការរកឃើញមួយចំនួនផងដែរ អំពីរបៀបដែលគ្រោះថ្នាក់ នៃជីវិតក្នុងពន្ធនាគារមានចំនួនច្រើនជាងគុណប្រយោជន៍ក្នុងការរក្សាទុកកុមារ នៅជិតម្តាយលើកលែងតែអ្នកទាំងនោះមានអាយុតិចជាង ៣ ឆ្នាំ ដូចមានចែងក្នុងច្បាប់កម្ពុជា។

កុមាររស់នៅក្នុងពន្ធនាគារនៅប្រទេសកម្ពុជា ជារឿយៗត្រូវបានសង្គមបំភ្លេចចោល។ កាន់តែធ្ងន់ធ្ងរជាងមុន កុមារជារឿយៗក៏មិនត្រូវបានយកចិត្តទុកដាក់ដោយអាជ្ញាធរ ដែលទទួលខុសត្រូវចំពោះអ្នកទាំងនោះដែរ។ ទាំងអគ្គនាយកដ្ឋានពន្ធនាគារ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទំនងជាមិនបានធ្វើការសិក្សាស្រាវជ្រាវបែបណាមួយទេ អំពីផលប៉ះពាល់ពីជីវិតនៅក្នុងពន្ធនាគារទៅលើការចំរើនលូតលាស់ខាងផ្លូវកាយ និងខាងផ្លូវចិត្តរបស់កុមារ។

ដោយសារកង្វះការសិក្សាស្រាវជ្រាវទាំងស្រុង លើប្រធានបទនេះក្នុងប្រទេសកម្ពុជា អង្គការលីកាដូ សង្ឃឹមថាអាជ្ញាធរ និងអង្គការជាដៃគូ នឹងអនុវត្តតាមការផ្តួចផ្តើមគំនិតនេះ ដោយចាត់វិធានការនានា ដើម្បីស្វែងយល់ និងលើកស្ទួយសិទ្ធិរបស់ស្ត្រីជាម្តាយ និងសិទ្ធិរបស់កុមារ នៅក្នុងពន្ធនាគារឲ្យកាន់តែប្រសើរឡើងពិនិត្យឡើងវិញនូវដំណើរការធ្វើសេចក្តីសម្រេច ដែលនាំឲ្យកុមារទៅរស់នៅជាមួយម្តាយរបស់អ្នកទាំងនោះនៅតាមពន្ធនាគារ ហើយនឹងធ្វើការវាយតម្លៃផលប៉ះពាល់ពីការឃុំខ្លួនក្នុងពន្ធនាគារទៅលើកុមារ។ អង្គការលីកាដូ ជឿជាក់ថាជាជំហានដំបូង ធនធានបន្ថែមត្រូវការលៃលកផ្តល់ដោយអគ្គនាយកដ្ឋានពន្ធនាគារ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីរៀបចំ និងលើកស្ទួយការសិក្សាស្រាវជ្រាវលើបញ្ហាសំខាន់នេះ[២] ។

# សាវតារ

នៅក្នុងខែកក្កដា ឆ្នាំ២០១៣ មានក្មេងចំនួន ៥១នាក់ អាយុចាប់ពី ១ ខែរហូតដល់ ៨ ឆ្នាំ កំពុងរស់នៅជាមួយម្តាយរបស់អ្នកទាំងនោះក្នុងពន្ធនាគារមួយចំនួន ដែលត្រូវបានឃ្លាំមើល ដោយអង្គការលីកាដូ[៣]។ ក្មេងចំនួន ១២ នាក់ ក្នុងចំណោមក្មេងទាំងនេះ មានអាយុលើសពី ៣ ឆ្នាំ ដែលផ្ទុយនឹងច្បាប់ស្តីពីពន្ធនាគារបានអនុម័ត ក្នុងខែធ្នូ ឆ្នាំ២០១១ ដែលបន្ថយចំនួនអាយុរបស់កុមារតាមម្តាយ ដែលត្រូវអនុញ្ញាតឲ្យស្នាក់នៅក្នុងពន្ធនាគារពីអាយុ ៦ ឆ្នាំមកក្រោមអាយុ ៣ ឆ្នាំ។ ច្បាប់នេះ ចែងផងដែរថា កុមារតាមម្តាយដែលមានអាយុចាប់ពី ៣ ឆ្នាំឡើង បើគ្មានអាណាព្យាបាលទទួលខុសត្រូវការចិញ្ចឹមបីបាច់ថែរក្សាបន្តនៅខាងក្រៅពន្ធនាគារទេ[៤] នោះគឺជាបន្ទុករបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

នេះទំនងថាប្រធានពន្ធនាគារមួយចំនួនមិនបានដឹង ឬមិនយកចិត្តទុកដាក់នឹងបទបញ្ញត្តិក្នុងច្បាប់ស្តីពីពន្ធនាគារនេះ។ ហើយអាចនិយាយបានផងដែរថា ប្រធានពន្ធនាគារខ្លះ មានអារម្មណ៍មិនសូវមានមធ្យោបាយ ដើម្បីដកហូតក្មេងចេញពីម្តាយ នៅពេលដែលក្មេងនោះមានអាយុដល់ ៣ ឆ្នាំ។ ប្រធានពន្ធនាគារត្រូវការជំនួយគាំទ្រពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្នុងបរិបទនេះ មិនគ្រាន់តែដើម្បីដឹកនាំការវាយតម្លៃទៅលើភាពអាណាព្យាបាលសមស្របប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីធានាថាការដកហូតក្មេងពីម្តាយជាប់ឃុំ ត្រូវតែធ្វើឡើងដោយសុភវិនិច្ឆ័យ និងតាមពេលវេលាសមស្រប ហើយលុះត្រាតែមានការរៀបចំ ដែលត្រូវបានធ្វើឡើងយ៉ាងសមស្រប។

រហូតមកទល់បច្ចុប្បន្ននេះ គេមិនបានដឹងថាមានការវាយតម្លៃទៅលើគ្រួសារណាមួយត្រូវបានធ្វើ ឡើងដោយអាជ្ញាធរជួណា

**នៅប្រទេសកម្ពុជាបញ្ហាមួយ គឺនៅតែជាបញ្ហាច្បាស់ក្រឡែតនោះគឺប្រព័ន្ធគ្រប់គ្រងពន្ធនាគារនៅប្រទេសកម្ពុជា មិនមានសមត្ថភាពក្នុងការផ្តល់ដល់កុមារ នូវសេចក្តីត្រូវការជាមូលដ្ឋានបំផុតរាប់ទាំងការអប់រំ ជីវិតគ្រួសារ អាហារូបត្ថម្ភ សមរម្យនិងការថែទាំខាងវេជ្ជសាស្ត្រនោះទេ។**

មួយនោះ ឬទេ ដើម្បីកំណត់ថាតើក្មេងគួរតែរស់នៅជាមួយម្តាយក្នុងពន្ធនាគារ ឬក្នុងករណីកូនកើតមកនៅពេលម្តាយជាអ្នកទោសពន្ធនាគារថាតើកូននោះគួរតែស្នាក់នៅជាមួយម្តាយក្នុងពន្ធនាគារ ឬយ៉ាង

[២] ការសិក្សាស្រាវជ្រាវនេះនឹងត្រូវធ្វើឡើងស្របតាមវិធាន ៦៨ នៃវិធានសហប្រជាជាតិសម្រាប់គ្រប់គ្រងអ្នកទោសជាស្ត្រី និងវិធានការមិនឃុំខ្លួនសម្រាប់ជនល្មើសជាស្ត្រី (វិធានក្រុងបាងកក) ដែលត្រូវបានអនុម័តដោយមហាសន្និបាតសហប្រជាជាតិ (សេចក្តីសម្រេច A/RES/65/29) នៅខែធ្នូ ឆ្នាំ២០១០។

[៣] អង្គការលីកាដូក្រោម Adopt-A –Prison Project របស់ខ្លួន បច្ចុប្បន្នធ្វើការលើពន្ធនាគារចំនួន ១៥ ក្នុងចំណោមពន្ធនាគារចំនួន ២៣ ក្នុងប្រទេសកម្ពុជាដែលផ្ទុកជនជាប់ឃុំជាស្ត្រី គឺពន្ធនាគារនៅខេត្តបាត់ដំបង បន្ទាយមានជ័យ កំពត កំពង់ចាម កំពង់ឆ្នាំង កំពង់សោម កំពង់ធំ កំពង់ស្ពឺ កោះកុង ពោធិ៍សាត់ ស្វាយរៀង សៀមរាប ក្រុងតាខ្មៅ ព្រមទាំងមណ្ឌលអប់រំកែប្រែទី២ និងពន្ធនាគារប៉េហ្ស៊ីនៅជាយរាជធានីភ្នំពេញ។ ចំនួនជនជាប់ឃុំសម្រាប់ពន្ធនាគារទាំង ១៥ នេះ តំណាងឲ្យចំនួនជនជាប់ឃុំជាង ៨០% សម្រាប់ពន្ធនាគារទាំង ២៣ ដែលផ្ទុកជនជាប់ឃុំជាស្ត្រី។

[៤] មាត្រា ៤១ នៃច្បាប់ស្តីពីពន្ធនាគារ។

ណា។ ក្នុងករណីភាគច្រើនម្តាយ ធ្វើការសម្រេចចិត្ត ថាតើ កូននឹងរស់នៅជាមួយអ្នកទាំងនោះក្នុងពន្ធនាគារ ឬយ៉ាងណា ហើយអាជ្ញាធរកម្រនឹងសួរដេញដោល អំពីការសម្រេចបែបនេះណាស់។ ជាអកុសល ការសម្រេចចិត្តរបស់ម្តាយជារឿយៗមិនត្រូវបានធ្វើតាមគោលការណ៍ផ្អែកលើឧត្តមប្រយោជន៍ល្អបំផុតរបស់កុមារទេ។

ការសម្រេចចិត្តដើម្បីអនុញ្ញាតឲ្យកុមារអាយុក្រោម ៣ ឆ្នាំស្នាក់នៅជាមួយម្តាយក្នុងពន្ធនាគារ គួរតែត្រូវធ្វើផ្អែកលើការវាយតម្លៃជាលក្ខណៈបុគ្គលទាំងស្រុង ហើយនឹងឧត្តមប្រយោជន៍ល្អបំផុតរបស់កុមារ[៩]។ នេះមានន័យថាអគ្គនាយកដ្ឋានពន្ធនាគារ និងក្រសួងសង្គមកិច្ចគួរតែគិតពិចារណាទៅលើស្ថានភាពគ្រួសារ និងវិធានការផ្សេងទៀតមុនពេលរក្សាទុកកុមារឬបញ្ជូនអ្នកទាំងនោះទៅពន្ធនាគារជាស្វ័យប្រវត្តិ។

តាមការពិតការវាយតម្លៃប្រភេទនេះ មិនដែលកើតមានឡើងនៅប្រទេសកម្ពុជានោះទេ។ កុមារអាចត្រូវបានបញ្ជូនទៅពន្ធនាគារ ដោយសារពួកគេមានវត្តមាននៅពេលចាប់ខ្លួន ទោះជាមានជម្រើសផ្សេងពីនេះសមស្របក៏ដោយ ឬក្មេងអាចត្រូវបញ្ជូនទៅពន្ធនាគារតាមការស្នើសុំពីម្តាយប៉ុណ្ណោះ ដោយគ្មានបានគិតគូរពីឧត្តមប្រយោជន៍ល្អបំផុតរបស់កុមារឡើយ។

មានបញ្ហាស្មុគស្មាញយ៉ាងច្រើនចំពោះកុមារ និងពន្ធនាគារ ប៉ុន្តែនៅប្រទេសកម្ពុជា បញ្ហាមួយ គឺនៅតែជាបញ្ហាច្បាស់នោះ គឺប្រព័ន្ធគ្រប់គ្រងពន្ធនាគារប្រទេសកម្ពុជាគ្មានសមត្ថភាព ក្នុងការផ្តល់ដល់កុមារនូវសេចក្តីត្រូវការជាមូលដ្ឋានបំផុត រាប់ទាំងការអប់រំ ជីវិតគ្រួសារ អាហារូបត្ថម្ភសមរម្យ និងការថែទាំខាងវេជ្ជសាស្ត្រ។ កុមារដែលនៅឯកកោពីប្រភពខាងក្រៅ និងទទួលអាហារូបត្ថម្ភមិនគ្រប់គ្រាន់ ជានិច្ចកាលប្រឈមនឹងបញ្ហាធ្ងន់ធ្ងរក្នុងការចំរើនលូតលាស់ ហើយប្រឈមនឹងពេលវេលាដ៏លំបាក ដើម្បីសម្របខ្លួនទៅក្នុងសង្គម នៅពេលពួកគេចាកចេញពីពន្ធនាគារ។

គិតមកត្រឹមខែកញ្ញា ឆ្នាំ២០១៣ នេះ មានតែពន្ធនាគារកម្ពុជាចំនួន ៤ ប៉ុណ្ណោះ ដែលបានផ្តល់ដល់កុមារនូវឱកាសកំសាន្ត និងឱកាសអប់រំជាមូលដ្ឋាននៅនឹងកន្លែង។ កម្មវិធីទាំងអស់នេះ ត្រូវបានរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន។ ជាការពិត ស្ទើរតែពុំមានវិធានការត្រូវបានធ្វើឡើងដោយ អាជ្ញាធរដើម្បីកែប្រែស្ថានភាពរបស់កុមារក្នុងពន្ធនាគារ ហើយកិច្ចខិតខំប្រឹងប្រែងភាគច្រើនបំផុត នៅតែបន្តដឹកនាំដោយអង្គការមិនមែនរដ្ឋាភិបាល។

ថ្វីបើមានហេតុការណ៍ ដែលថាពន្ធនាគារកម្ពុជា មិនបានផ្តល់ដល់កុមារទាល់តែសោះនូវបរិយាកាសសមស្របក៏ដោយ ក៏ស្ត្រីមានផ្ទៃពោះ និងស្ត្រីមានកូននៅជាមួយ កម្រនឹងទទួលបានការជៀសវាងពីការជាប់ឃុំ ឬនៅក្រៅឃុំរង់ចាំសវនាការណាស់ ដើម្បីបានថែរក្សាក្រុមគ្រួសារ។ នេះជាការពិតសូម្បីតែក្នុងករណីបទលហុ ដែលជាវិធានការផ្សេងទៀតដ៏មានប្រសិទ្ធិភាពយុត្តិធម៌ ដូចជា ការធ្វើការងារសង្គមជាដើម។

ចំពោះជនជាប់ឃុំជាស្ត្រីមានផ្ទៃពោះ និងជាម្តាយចំនួន ៦៤ នាក់ ដែលអង្គការលីកាដូ បានឃ្លាំមើលគិតមកត្រឹមខែកក្កដា ឆ្នាំ ២០១៣ នេះ អ្នកទាំងនោះលើកលែងតែ ៣ នាក់ ប៉ុណ្ណោះ ត្រូវបានឃុំខ្លួនពីបទជួញដូរគ្រឿងញៀន ចោរកម្ម ឬបទពេស្យាកម្ម។ ស្ត្រីទាំងនេះចំនួនលើសពីពាក់កណ្តាល កំពុងតែត្រូវបានឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការនៅឡើយ។

[៩] វិធាន ៤៩ និង៥២ នៃវិធានក្រុងបាងកក ហើយនឹងមាត្រា ៣(១) នៃអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិកុមារ។



ក្មេងប្រុសអាយុ ៦ឆ្នាំ ម្នាក់រស់នៅក្នុងមណ្ឌលអប់រំកែប្រែទី២

# កុមារភាពនៅក្នុងពន្ធនាគារ

## វិធីសាស្ត្រសិក្សាស្រាវជ្រាវ

ដោយមានជំនួយពីមជ្ឈមណ្ឌលអភិវឌ្ឍកុមារ នៃអង្គការ INDIGO[៦] សុខ គុន (មិនមែនឈ្មោះពិត) បានចូលរួមក្នុងការវាយតម្លៃក្នុងខែមិថុនា ឆ្នាំ២០១៣ ដើម្បីពិនិត្យមើលមុខងារចិត្តវិទ្យារបស់គាត់ ដោយផ្តោតយកចិត្តទុកដាក់លើផលប៉ះពាល់ ពីពេលវេលាឃុំខ្លួនរបស់គាត់ក្នុងពន្ធនាគារ។

អង្គការ INDIGO បានធ្វើកិច្ចសាកសួរពិគ្រោះជាលក្ខណៈ បុគ្គលជាមួយ សុខ គុន ព្រមទាំងបានធ្វើកិច្ចសម្ភាសន៍ជាមួយម្តាយ គាត់ក្នុងពន្ធនាគារជាមួយគ្រូ និងបុគ្គលិកពីអង្គការ Chibodia[៧] ជាអង្គការមិនមែនរដ្ឋាភិបាល។ ម្តាយ សុខ គុន ដែលជាអ្នកថែទាំគាត់ និងគ្រូបានបំពេញបញ្ជីសំណួរពីភាពលំបាក និងភាពខ្លាំងរបស់គាត់ (SDQ)[៨]។ កម្រិតវាស់ស្ទង់ការព្រួយបារម្ភរបស់កុមារ (SCAS)[៩] ត្រូវបាន គេយកមកប្រើផងដែរ ដែលជាឧបករណ៍សម្រាប់វាយតម្លៃទៅលើកម្រិតនៃជម្ងឺព្រួយបារម្ភរបស់ សុខ គុន។

អ្នកថែរក្សាបឋមរបស់ សុខ គុន បានកត់ត្រាទុកនូវឥរិយាបថរបស់គាត់ បន្ទាប់ពីចាកចេញពីពន្ធនាគារ ហើយបានធ្វើការកត់សម្គាល់ពីឧបទ្ទវហេតុសំខាន់ៗទាំងវិជ្ជមាន និងអវិជ្ជមាន។ ដំណើរនេះ ត្រូវបានប្រើផងដែរ ជាប្រភពព័ត៌មានសម្រាប់ករណីសិក្សានេះ។

គ្រប់ព័ត៌មាន និងទិន្នន័យទាក់ទងនឹងពន្ធនាគារ ត្រូវបានផ្តល់ដោយអង្គការលីកាដូ។ អ្នកស្រាវជ្រាវពន្ធនាគារអង្គការលីកាដូ បានចុះទៅពិនិត្យមើលមណ្ឌលអប់រំកែប្រែទី២ ស្ទើរតែរាល់សប្តាហ៍នៅពេល សុខ គុន រស់នៅទីនោះ។

## សាវតារគ្រួសារ

ម្តាយរបស់ សុខ គុន មានអាយុ ២៨ ឆ្នាំ ហើយគាត់មានគភ៌ ៧ ខែ នៅពេលគាត់ត្រូវ

[៦] សម្រាប់ព័ត៌មានបន្ថែម សូមមើល http://www.indigo-cambodia.com។
[៧] សម្រាប់ព័ត៌មានបន្ថែម សូមមើល http://www.chibodia.org។
[៨] បញ្ជីសំណួរពីភាពលំបាក និងភាពរឹងប៉ឹង (SDQ) គឺជាឧបករណ៍ពិនិត្យមើលឥរិយាបថ ជាពិសេសអំពីកុមារដែលមនគោលដៅផ្តល់ការវាយតម្លៃបឋមពីសុខុមាលភាព ខាងចិត្តវិទ្យាទូទៅរាប់ទាំងសភាវៈគតិ ភស្តុតាងនៃសកម្មភាពហួសហេតុ សំពាធពីមិត្តភក្តិ និងកំរិតឥរិយាបថដែលគាំទ្រដោយសង្គម។
[៩] រាប់ព័ត៌មានបន្ថែម សូមមើល http://www.scaswebsite.com។

### ជីវប្រវត្តិរបស់ សុខ គុន

សុខ គុន ភេទប្រុស បានរស់នៅជាមួយម្តាយក្នុងពន្ធនាគារ រហូតដល់គេមានអាយុ ៦ ឆ្នាំ ១០ ខែ។ នៅពេលនោះច្បាប់កម្ពុជាបានអនុញ្ញាតឲ្យក្មេងៗ ស្នាក់នៅជាមួយម្តាយរបស់ពួកគេក្នុងពន្ធនាគាររហូតដល់អាយុ ៦ ឆ្នាំ។ ដោយមាន ជំនួយពីអង្គការលីកាដូ សុខ គុន បានរស់នៅជាមួយអង្គការ Chibodia ជាអង្គការមិនមែនរដ្ឋាភិបាលចាប់តាំងពីខែមករា ឆ្នាំ ២០១២ ដោយសារម្តាយរបស់សុខ គុន ពុំមានបងប្អូនណាអាចបីបាច់ថែទាំគេ នៅខណៈម្តាយកំពុងជាប់ទោសនៅសល់ចំនួន ១៥ ឆ្នាំទៀត។

នៅក្នុងពន្ធនាគារ សុខ គុន ជាញឹកញាប់ត្រូវបានគេចាក់សោទុកក្នុងបន្ទប់ឃុំខ្លួនដែលមានភាពចង្អៀតណែន និងក្តៅមិនឲ្យចេញជាច្រើនម៉ោងរៀងរាល់ថ្ងៃ។ គេបានរស់នៅក្នុងបរិយា កាសតឹងតែង និងប្រកបដោយហិង្សាដែលជាទីកន្លែងមានការវាយតប់គ្នា ការជេរប្រមាថគ្នា និងការលែងល្បែងបានកើតឡើងជាធម្មតា។ ជាញឹកញាប់គេឃ្លានអាហារ ខ្វះការអប់រំ និងគ្មានអន្តរកម្មខាងសង្គមប្រកប ដោយអត្ថន័យឡើយ។

បានចាប់ខ្លួនក្នុងខែមករា ឆ្នាំ២០០៥ ពីបទជួញដូរមនុស្ស។ គាត់ត្រូវបានបញ្ជូនទៅពន្ធនាគារខេត្តកំពង់ចាម ជាមួយកូនប្រុសច្បងរបស់គាត់អាយុ ៦ ឆ្នាំនៅពេលនោះ។ ចំនួន ២ ខែក្រោយមក គឺក្នុងខែមីនា សុខ គុន ក៏បានកើតនៅក្នុងមន្ទីរពេទ្យ ខេត្តកំពង់ចាម ហើយក៏ត្រូវបានផ្ទេរជាមួយម្តាយទៅកាន់ពន្ធនាគារ ខេត្តកំពង់ចាមវិញ។ ភ្លាមៗបន្ទាប់ពី សុខ គុន បានកើតមកម្តាយគេក៏បានបញ្ជូនកូនប្រុសច្បងឲ្យទៅរស់នៅជាមួយបងប្អូនប្រុសរបស់គាត់ម្នាក់នៅខេត្តព្រៃវែង ប៉ុន្តែពួកគេក៏លែងទាក់ទងគ្នាបាន។ សុខ គុន មិនដែលបានជួបមុខបងប្រុសរបស់គេឡើយ ហើយម្តាយគេក៏មិន ដែលបានទទួលដំណឹងពីកូនប្រុសច្បងនេះដែរ។ អស់រយៈពេល ៧ ខែ ក្រោយមក សុខ គុន និងម្តាយរបស់គេត្រូវបានបញ្ជូនមកកាន់មណ្ឌលអប់រំកែប្រែទី ២ ជាពន្ធនាគារតែមួយគត់នៅកម្ពុជា ដែលផ្ទុកជនជាប់ឃុំជាស្ត្រី និងអនីតិជនតែប៉ុណ្ណោះ។ គ្មានហេតុផលត្រូវបានប្រាប់ឲ្យដឹងចំពោះការផ្ទេរអ្នកទាំងពីរឡើយ។

យាយតារបស់ សុខ គុន ដែលជាឪពុកម្តាយរបស់ម្តាយ សុខ គុន បានទទួលមរណភាពនៅ ពេលម្តាយ សុខ គុន ទើបតែមានអាយុ ៣ ឆ្នាំ ហើយមិនមានការបញ្ជាក់ឲ្យបានច្បាស់ ថាអ្នកណាចិញ្ចឹមបីបាច់ម្តាយ សុខ គុន និងបងប្អូនប្រុសចំនួន ៥ នាក់ របស់គាត់ទេនៅពេលនោះ។ ឪពុកបង្កើតរបស់ សុខ គុន បានស្លាប់ក្នុងឆ្នាំ២០០៨ ក្នុងស្ថានភាពមិនអាចដឹងបាន នៅពេលគាត់ព្យាយាមឆ្លងកាត់ព្រំដែនកម្ពុជា-ថៃ។

ទាំងអង្គការលីកាដូ និងអង្គការ Chibodia បានធ្វើការវាយតម្លៃទៅលើផលប៉ះពាល់ពីបទពិសោធន៍ពន្ធនាគារទាំងនេះទៅលើ សុខ គុន។ ការវាយតម្លៃនេះមានគោលបំណង២ ប្រការ។ គោលបំណងទី១ វាបានផ្តល់ដល់អង្គការទាំង ២ នេះនូវការយល់ដឹងជាសារវ័ន្តអំពីក្មេងៗ ដែលរស់នៅក្នុងពន្ធនាគារនៅប្រទេសកម្ពុជា។ គោលបំណងទី២ វាបានផ្តល់ដល់អង្គការ Chibodia នូវអនុសាសន៍ជាក់លាក់ទាំងឡាយសម្រាប់ការថែទាំ សុខ គុន ទៅអនាគត។ អនុសាសន៍ជាក់លាក់ ទាំងនេះមិនបានដាក់បញ្ចូលក្នុងរបាយការណ៍នេះទេ សម្រាប់ហេតុផលរក្សាការសម្ងាត់ និងភាពអាចអនុវត្តបាន។

# ស្ថានភាពមន្ទីរឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី២

មណ្ឌលអប់រំកែប្រែទី២ គឺជាពន្ធនាគារមួយក្នុងចំណោមពន្ធនាគារទាំងឡាយ ដែលមានភាពចង្អៀតណែនបំផុត នៅប្រទេសកម្ពុជា។ ចំពេលចំនួនមនុស្សច្រើនបំផុត នៅខណៈ សុខ គុន បានរស់នៅទីនោះ មណ្ឌលអប់រំកែប្រែទី២ នេះបានផ្ទុកជនជាប់ឃុំចំនួន ៨១៤ នាក់ ស្មើនឹង ២៧១% នៃទំហំផ្ទុកជនជាប់ឃុំ ដែលអាចទទួលបានតែប្រហែល ៣០០ នាក់ប៉ុណ្ណោះ។



ប៉ុស្តិ៍សុខភាពនៅក្នុងមណ្ឌលអប់រំកែប្រែទី២ ជាកន្លែងសុខ គុន រស់នៅ

រហូតដល់ឆ្នាំ២០០៨ ជនជាប់ឃុំជាម្តាយ ដែលរស់នៅជាមួយកូនៗរបស់គេក្នុងពន្ធនាគារ និងស្ត្រីមានផ្ទៃពោះត្រូវបានគេដាក់លាយឡំជាមួយជនជាប់ឃុំជាទូទៅ ហើយពួកគេទទួលរងនូវស្ថានភាពស្មោកគ្រោក ដូចគ្នានឹងជនជាប់ឃុំផ្សេងៗទៀតទាំងអស់ ដោយរស់នៅក្នុងបន្ទប់ចង្អៀតណែន និងកខ្វក់ខ្យល់ចេញចូល និងពន្លឺថ្ងៃធម្មជាតិមានកម្រិត។

នៅក្នុងឆ្នាំ២០០៨ ប្រធានមណ្ឌលអប់រំកែប្រែទី២ បានដកជនជាប់ឃុំជាម្តាយជាមួយកូនៗរបស់ពួកគេ និងស្ត្រីមានគភ៌រយៈពេលជាង ៥ ខែ ទាំងអស់ចេញពីបន្ទប់ឃុំខ្លួនធម្មតា ទៅរស់នៅក្នុងប៉ុស្តិ៍សុខភាពក្នុងពន្ធនាគារ ដែលនៅពេលនោះមានតែបន្ទប់ក្នុងប៉ុស្តិ៍សុខភាពប៉ុណ្ណោះ ដែលជាជម្រើសផ្សេងពីពន្ធនាគារ។

ប៉ុស្តិ៍សុខភាពនេះ ស្ថិតនៅក្នុងរបងពន្ធនាគារ ប៉ុន្តែត្រូវបានយកចេញខ្លះពីបន្ទប់ឃុំខ្លួនផ្សេងៗទៀត និងទីធ្លាសំខាន់ៗ។ ប៉ុស្តិ៍សុខភាពចែកចេញជា ៤ បន្ទប់ ហើយបន្ទប់នីមួយៗមានទំហំប្រហែលជា ៩ ម៉ែត្រការ៉េ ដោយមានទីធ្លាតូចចង្អៀតជាមួយនឹងបង្គន់នៅផ្នែកខាងក្រៅ។ មានបន្ទប់ពិនិត្យជម្ងឺ ១ សម្រាប់ជនជាប់ឃុំកើតជម្ងឺឆ្លង ហើយមានបន្ទប់ ២ ផ្សេងទៀតប្រើសម្រាប់ជនជាប់ឃុំជាអ្នកជម្ងឺផ្សេងៗទៀត អ្នកជម្ងឺជាស្ត្រី ព្រមទាំងស្ត្រីមានគភ៌។

ប៉ុស្តិ៍សុខភាពអាចផ្តល់ស្ថានភាពរស់នៅ ប្រសើរជាងបន្ទប់ឃុំខ្លួនធម្មតាបន្តិច ប៉ុន្តែនៅតែមានការព្រួយបារម្ភជាក់ស្តែងទាក់ទងនឹងការចល័តកុមារ និងស្ត្រីមានគភ៌ ឲ្យទៅរស់នៅជិតជនជាប់ឃុំដែលកើតជម្ងឺឆ្លងបែបនេះ។ អាចជាលទ្ធផល ដោយផ្ទាល់ពីការចល័តនេះ ទារក ២ នាក់ បានឆ្លងរោគរបេង ដែលអាចជាការគម្រាមកំហែងដល់ជីវិតក្មេងតូចៗ។ ទារកទាំង ២ នាក់នេះកំពុងត្រូវបានព្យាបាលដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយ។

នៅចន្លោះឆ្នាំ២០០៨ និងខែមករា ឆ្នាំ២០១២ ជាមធ្យមមានកុមារចំនួន ១៣ នាក់ស្ត្រីជាម្តាយចំនួន ១៣ នាក់ និងស្ត្រីមានគភ៌ចំនួន ៦ នាក់ត្រូវបានគេដាក់ក្នុងបន្ទប់ចំនួន ២ នៅក្នុងប៉ុស្តិ៍ សុខភាព រួមជាមួយអ្នកជម្ងឺផ្សេងទៀតជាស្ត្រីផងដែរ។

សូម្បីតែអ្នកជម្ងឺជាស្ត្រី និងទីធ្លាដែលត្រូវការបន្ថែមសម្រាប់កុមារ ក៏មិនត្រូវបានលើកយកមកពិចារណាផងនោះ ប្រការនេះបកស្រាយថា មានទំហំទីធ្លារស់នៅមិនដល់ ១ ម៉ែត្រការ៉េផង សម្រាប់ជនជាប់ឃុំជានីតិជនម្នាក់ៗ។ ចំពេលចំនួនមនុស្សច្រើនបំផុត មានកុមារចំនួន ១៩នាក់ កំពុងរស់នៅជាមួយម្តាយរបស់អ្នកទាំងនោះ ហើយនឹងមានជនជាប់ឃុំជាស្ត្រីមានគភ៌ចំនួន ១០ នាក់។

ទោះជាបទដ្ឋានអន្តរជាតិមិនបានកំណត់អប្បបរមា នូវទំហំផ្ទៃទីធ្លាកម្រាលឥដ្ឋ ឬទំហំផ្ទៃដីជាម៉ែត្រគីបសំរាប់ជនជាប់ឃុំ ក៏ដោយក៏គណៈកម្មាធិការអឺរ៉ុបបង្ការទារុណកម្ម បានផ្តល់អនុសាសន៍យ៉ាងតិចណាស់ត្រូវមានទំហំផ្ទៃទីធ្លាចំនួន ៤ ម៉ែត្រការ៉េ សម្រាប់ជនជាប់ឃុំ[១០]ម្នាក់ៗ ចំពោះបន្ទប់ឃុំខ្លួន ដែលមានចំនួនជនជាប់ឃុំច្រើននាក់ ។ គណៈកម្មាធិការអន្តរជាតិកាកបាទក្រហមបានថ្លែងថា " សូម្បីតែស្ថិតក្នុងស្ថានភាពមានវិបត្តិពិសេសក៏ដោយ ក៏ទំហំផ្ទៃទីធ្លាកម្រាលឥដ្ឋក្នុងបន្ទប់ឃុំខ្លួន ឬ បន្ទប់សម្រាប់សម្រាក មិនត្រូវតូចជាង ២ ម៉ែត្រការ៉េសម្រាប់មនុស្សម្នាក់ឡើយ"[១១]។

## សុខ គុន មិនបាននិយាយច្រើនទេអំពីអតីតកាលរបស់គេ កាលណាគេនិយាយគេនឹង និយាយយោងដល់ពន្ធនាគារថាជា “ទ្រុង” មួយ។

នៅក្នុងពន្ធនាគារ សុខ គុន បានចំណាយពេលជាច្រើនថ្ងៃក្នុងមណ្ឌលថែទាំប្រចាំថ្ងៃ ដែលនៅជាប់នឹងពន្ធនាគារ និងត្រូវបានរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាលមួយ។ នៅមណ្ឌលនេះ សុខ គុន ត្រូវបានគេផ្តល់ម្ហូបអាហារបន្ថែម ហើយអាចលេងកំសាន្តបាន។ ប៉ុន្តែនៅពេលថ្ងៃ ពេលដែលមណ្ឌលនេះបិទនៅរាល់ចុងសប្តាហ៍ សុខ គុន ត្រូវបានអនុញ្ញាតឲ្យនៅក្រៅបន្ទប់ឃុំខ្លួន នៅពេលទ្វារបន្ទប់បើករយៈពេល ៤ ម៉ោងពេលព្រឹក និង ២ ម៉ោងពេលល្ងាច។ សុខ គុន បានចំណាយពេលចំនួន ១៩ ម៉ោងផ្សេងទៀតជារៀងរាល់ថ្ងៃនៅក្នុងបន្ទប់ឃុំខ្លួន ដែលមានសភាពចង្អៀតណែន និងក្តៅ។

នៅក្នុងខែឧសភា ឆ្នាំ២០១៣ រយៈពេល ១៧ ខែ បន្ទាប់ពី សុខ គុន បានចាកចេញពីពន្ធនាគារ អគារថ្មីចំនួន ២ ត្រូវបានដាក់សម្ពោធឲ្យប្រើប្រាស់ក្នុងមណ្ឌលអប់រំកែប្រែទី២ ជាពិសេសសម្រាប់ផ្ទុកជនជាប់ឃុំជាស្ត្រីមានគភ៌ និងស្ត្រីដែលរស់នៅក្នុងមណ្ឌលនេះជាមួយកូនៗ របស់អ្នកទាំងនោះ។ ជាលទ្ធផលស្ថានភាពឃុំខ្លួនសម្រាប់ស្ត្រី និងកុមារបច្ចុប្បន្ននេះ មានភាពប្រសើរឡើង ។

## ស្លាកស្នាមជីវិតនៅក្នុងពន្ធនាគារ

នៅអំឡុងពេលធ្វើការវាយតម្លៃដោយអង្គការ INDIGO សុខ គុន មិនបាននិយាយច្រើនទេ អំពីអតីតកាលរបស់គេ។ កាលណាគេនិយាយ គេនឹងនិយាយយោងដល់ពន្ធនាគារថាជា "ទ្រុង" មួយ។ ការបញ្ជាក់នេះ ត្រូវបានគូសបង្ហាញដោយលទ្ធផលនៃកម្រិតវាស់ស្ទង់ការព្រួយបារម្ភរបស់កុមារ (SCAS) ដែលបង្ហាញនូវបន្ទុកខ្ពស់ចំពោះពិន្ទុបន្ទាប់បន្សំអំពីការខ្លាចទីធ្លាទូលាយ (Sub-Scales Panic/ Agoraphobia) មានន័យថាការភ័យខ្លាចក្នុង ការស្ថិតនៅក្នុងទីកន្លែងមួយ ដែលមនុស្សមិនអាចចាកចេញពីទីនោះបានដោយងាយៗ។ ប្រការដែលត្រូវបានចាក់សោរបង្ខាំងជីវិតរបស់គេទុកក្នុងបន្ទប់ឃុំខ្លួនដែលតូចចង្អៀតណែនជាច្រើនម៉ោង ទំនងជាមានផលប៉ះពាល់យ៉ាងធ្ងន់ទៅលើជីវិតរបស់ សុខ គុន ហើយការចាក់សោរបង្ខាំងនេះ នៅតែត្រួតត្រាទៅលើការភ័យខ្លាចរបស់គេរហូតមកទល់បច្ចុប្បន្ននេះ។

សុខ គុន នៅតែមានការសុបិនអាក្រក់ និងនឹកឃើញស្រមោលអតីតកាលពីឧបទ្ទវហេតុមួយ ដែលប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំងដែលគេបានឃើញផ្ទាល់ភ្នែកក្នុងពន្ធនាគារ នៅពេល ដែលម្តាយរបស់គេបានកាត់ចំណង ដាក់សាកសពស្ត្រីម្នាក់ធ្វើអត្តឃាតចងកចុះមកក្រោម។ អ្នកថែទាំរបស់ សុខ គុន រាយការណ៍ថា សុខ គុន នៅតែទទួលរងអាការៈតក់ស្លុតធ្ងន់ធ្ងរទាក់ទងនឹងព្រឹត្តិការណ៍នេះ។ អាការៈទាំងនេះ ត្រូវការឃ្លាំមើលយ៉ាងដិតដល់ ដោយសារតែ ប្រសិនបើអាការៈទាំងនេះកាន់តែកើនឡើងអាការៈទាំងនេះ អាចវិវឌ្ឍន៍ជាវិបល្លាសស្មារតី ដែលមានភាពតក់ស្លុតធ្ងន់ធ្ងរ។

សុខ គុន បានបញ្ចេញឲ្យឃើញនូវឥរិយាបថស្រើបស្រាលនៅពេលគេបានមកកាន់ផ្ទះថ្មី លើកដំបូង ហើយបានបង្ហាញឲ្យឃើញនូវចំណេះដឹងខាងរួមភេទយ៉ាងច្រើនលើសពីអាយុសមស្រប។ មានឧបទ្ទវហេតុមួយចំនួនផងដែរនៅពេល សុខ គុន ដើរទៅកាន់បន្ទប់ទឹកជាមួយក្មេង ស្រីម្នាក់ ហើយគេបានប៉ុនប៉ងរួមភេទជាមួយក្មេងស្រីនោះ។ បុគ្គលិកបានគិតថានៅពេលពួកគេនិយាយទៅកាន់ សុខ គុន ដោយផ្ទាល់ និងបានពន្យល់ពីមូលហេតុ ដែលឥរិយាបថនេះ មិនសមរម្យនោះ សុខ គុន ក៏បានយល់ហើយបានឆ្លើយតបយ៉ាងត្រឹមត្រូវ។

សុខ គុន ចងចាំថាបានឃើញការវាយតប់គ្នាទាក់ទងនឹងអាហារ លុយកាក់ និងការលេងល្បែងស៊ីសងក្នុងពន្ធនាគារ។ ទង្វើនេះ ត្រូវបានឆ្លុះបញ្ចាំងក្នុងកម្រិតវាស់ស្ទង់ការព្រួយបារម្ភរបស់កុមារ (SCAS) ដែលបង្ហាញលទ្ធផលខ្ពស់ចំពោះការភ័យខ្លាចរងរបួសរាងកាយទំនងដោយសារបរិយាកាសហិង្សា និងប្រកបដោយហានិភ័យក្នុងពន្ធនាគារ។ បទពិសោធន៍ទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងផងដែរ ក្នុងឥរិយាបថបច្ចុប្បន្នរបស់គេចំពោះអាហារ និងលុយកាក់។

សុខ គុន រំលឹកថាជាញឹកញាប់គេឃ្លាន និងបារម្ភពីអាហារ[១២]។ តាមសេចក្តីរាយការណ៍បច្ចុប្បន្ននេះ សុខ គុន នៅតែ

[១០] សូមមើល http://www.coe.int/t/commissioner/viewpoints/070305_en.asp។
[១១] គណៈកម្មាធិការអន្តរជាតិកាកបាទក្រហម “ទឹក អនាម័យ និងលំនៅដ្ឋានក្នុងពន្ធនាគារ” ខែសីហា ឆ្នាំ២០០៥ ទំព័រ២១។
[១២] អនុក្រិត្យឆ្នាំ២០០៩ ស្តីពី “របបអាហារអ្នកទោស និងសម្ភារៈបន្ទប់ឃុំខ្លួន” បញ្ញត្តិអំពីថវិកាសម្រាប់អ្នកទោសម្នាក់ៗ ដែលពន្ធនាគារត្រូវទទួលបាន។ អ្នកទោសម្នាក់ៗត្រូវទទួលបានថវិកា ២,៨០០រៀល ក្នុង ១ ថ្ងៃ (០,៧០ ដុល្លារ) ហើយអ្នកទោសជាម្តាយត្រូវទទួលបាន ១,៤០០ រៀល (០.៣៥ដុល្លារ) បន្ថែមសម្រាប់កូនម្នាក់ៗក្នុង ១ ថ្ងៃ។ ជាញឹកញាប់ពន្ធនាគារមិនបានទទួលរបបថវិកាពេញលេញ ដូចដែលមានចែងក្នុងអនុក្រិត្យនេះទេ។ប្រសិនបើពួកគេទទួលបានរបបថវិកាពេញលេញមែន ក៏គ្មានការធានា ថាថវិកានេះ នឹងត្រូវចំណាយទៅលើម្ហូបអាហារសម្រាប់អ្នកទោសឡើយ។

លួចអាហារ និងលុយកាក់ពីផ្ទះថ្មីរបស់គេ និងពីសហគមន៍ បើទោះបីគេដឹងពីផលវិបាកអវិជ្ជមានក៏ដោយ។ សុខ គុន បានបញ្ចុះបញ្ចូលក្មេងៗ ដែលមានអាយុតិចជាងខ្លួនជាច្រើនដងផងដែរ ដើម្បីលួចអាហារយកមកឲ្យគេបរិភោគនៅមណ្ឌលកុមារ។

សុខ គុន មានការចងចាំជាវិជ្ជមានតែមួយគត់ពីពន្ធនាគារ គឺទាក់ទងនឹងមិតភក្តិ ២ នាក់ ដែលគេចូលចិត្តលែងជាមួយ។ ជាការសោកសៅមិត្តភក្តិគេម្នាក់ក្នុងចំណោមមិត្តភក្តិទាំង ២ បានលង់ទឹកស្លាប់ក្នុងទន្លេនៅរាជធានីភ្នំពេញកាលពី ២ ឬ ៣ ខែកន្លងទៅបន្ទាប់ពីគេបានចាកចេញពីពន្ធនាគារ។ សុខ គុន ដែលបានចាកចេញពីពន្ធនាគារមុនមិត្តភក្តិរបស់គេបន្តិច បានចូលរួមពិធីបុណ្យសពនេះ។ ព្រឹត្តិការណ៍ជីវិតប៉ះទង្គិចផ្លូវចិត្តនេះ អាចឲ្យយល់បានថា រហូតមកទល់ពេលនេះ សុខ គុន មិនអាចចំណាំឈ្មោះមិត្តភក្តិពិសេសណាម្នាក់នៅឯផ្ទះកុមារទាំងនេះ។

**អ្នកថែទាំរបស់ សុខ គុន រាយការណ៍ថាប្រសិនបើមនុស្សដទៃ និយាយតបយ៉ាងហិង្សាបំពានទៅលើរូបគេ គេមានអារម្មណ៍ភ័យខ្លាច និងញ័រខ្លួន។**

## ការអប់រំ និងទំនាក់ទំនងមិត្តភក្តិ

សុខ គុន បានចាប់ផ្តើមចូលសាលារដ្ឋ នៅរាជធានីភ្នំពេញភ្លាមបន្ទាប់ពីគេបានចាកចេញពីពន្ធនាគារ ដោយចាប់ផ្តើមចូលរៀនសាលាមត្តេយ្យជាមួយក្មេងៗដែលមានអាយុតិចជាងខ្លួន ២ ឆ្នាំ ដើម្បីសិក្សាឲ្យទាន់គេ ខណៈខ្លួនគេរស់នៅក្នុងពន្ធនាគារមិនបានសិក្សា។ ដំបូងគេខំតស៊ូយ៉ាងខ្លាំងក្នុងគ្រឹះស្ថានអប់រំ ដែលមានរចនាសម្ព័ន្ធច្រើនជាង។ តាមសេចក្តីរាយការណ៍ សុខ គុន បានរករឿងគ្រូ និងសិស្សដែលមានអាយុស្រករគ្នា ដើម្បីទទួលបានការប្រតិកម្មតប។ សុខ គុន ទទួលរងការលំបាកផ្លូវអារម្មណ៍នៅក្នុងថ្នាក់រៀនឆាឆៅ និងធ្វើឲ្យសិស្សអាយុស្រករគ្នាបែកអារម្មណ៍។

សព្វថ្ងៃ សុខ គុន ងាយនឹងបែកអារម្មណ៍ ហើយត្រូវការកើនរំលឹកបន្ថែមនៅសាលា ប៉ុន្តែគេនិយាយតបបានល្អ ហើយនឹងបានរៀនផ្លូវអារម្មណ៍ឡើងវិញ។ ឥឡូវការបំពេញការងារសាលាជាទូទៅ និងកម្រិតអប់រំរបស់គេមានប្រៀបស្មើនឹងការងារសាលា និងកម្រិតអប់រំរបស់ក្មេងៗ ដទៃទៀតនៅក្នុងថ្នាក់ ប៉ុន្តែនៅអាយុ ៨ ឆ្នាំ សុខ គុន នៅតែកំពុងចូលរៀននៅសាលាមត្តេយ្យជាមួយក្មេងៗ ដែលមានអាយុទាបជាងខ្លួននៅឡើយ។

នៅឯផ្ទះរបស់កុមារជាញឹកញាប់ សុខ គុន លេងកំសាន្តតែម្នាក់ឯង ដោយមិនលេងចូលជាមួយក្មេងៗស្រករខ្លួនទេ។ តាមសេចក្តីរាយការណ៍ នៅពេលគេលេងជាមួយក្មេងៗ ផ្សេងទៀត សុខ គុន ចូលចិត្តលេងជាមួយក្មេងៗដែលមានអាយុតិចជាងខ្លួន ហើយចូលចិត្តធ្វើជាមេគេ ដើម្បីអាចត្រួតត្រាសកម្មភាពលេងកំសាន្តទាំងនោះ។

ផ្អែកលើលទ្ធផលនៃកម្រងសំនួរ SDQ ម្តាយ របស់ សុខ គុន និងអ្នកថែទាំរបស់គេនៅផ្ទះកុមារ វាយតម្លៃពីការលំបាករបស់គេក្នុងការចុះសម្រុងជាមួយក្មេងៗដទៃទៀតមានកម្រិតខ្ពស់ណាស់។ គ្រូ និងអ្នកថែទាំរបស់គេ នៅតែដាក់បន្ទុកការលំបាកខាងឥរិយាបទរបស់គេមានកម្រិតខ្ពស់ណាស់ផងដែរ ជាពិសេសសកម្មភាពលួច និងការឆេវឆាវរបស់ សុខ គុន។

តាមដែលដឹងមក សុខ គុន នៅតែរករឿង និងឆាឆៅក្មេងៗដទៃទៀត ដែលមានអាយុស្រករគេ ដែលជារឿយៗ បណ្តាលឲ្យកើតជម្លោះពាក្យសំដី និងខាងរាងកាយ ហើយវាជារឿង ធម្មតាដែល សុខ គុន ស្រែក និងរុញច្រានក្មេងៗដទៃទៀត។ នៅពេលមានការវាយតប់គ្នា សុខ គុន ទំនងជាសម្តែងឲ្យឃើញនូវឥ រិយាបថគ្រោតគ្រាតបំពារបំពានច្រើន បើប្រៀបធៀបនឹងក្មេងៗ ដទៃទៀត ដែលមានអាយុស្រករគ្នា។ តាមដឹងមក ទង្វើបែបនេះ មិនមានការភ្ញាក់ផ្អើលទេ ដោយសារអំពើហិង្សាគេទទួលរង នៅអំឡុងពេលគេកំពុងចម្រើនវ័យអស់រយៈពេលជាច្រើនឆ្នាំនៅក្នុងពន្ធនាគារ។ អ្នកថែទាំ សុខ គុន រាយការណ៍ថា ប្រសិនបើអ្នកដទៃនិយាយតបតាមរបៀបបំពារបំពានមកលើគេ សុខ គុន មានអារម្មណ៍ភ័យខ្លាច ហើយនឹងញ័រខ្លួន។

សុខ គុន បន្តបង្ហាញឲ្យឃើញផងដែរ នូវឥរិយាបថឆេវឆាវច្រើនជាងអាយុសមស្រប ហើយមានលក្ខណៈការពារខ្លួនណាស់។ គេស្គាល់ពាក្យពេចន៍ជេរប្រមាថ ហើយជារឿយៗគេជេរប្រមាថច្រើនជាងក្មេងៗមានវ័យស្រករគ្នា។

## ម្តាយ និងចំណងទាក់ទងជាមួយកូន

សុខ គុន ហាក់ដូចជាមានចំណងទាក់ទងយ៉ាងល្អជាមួយម្តាយរបស់គេ ដោយសារគេអាចចំណាយពេលរស់នៅក្នុងពន្ធនាគារជាមួយម្តាយគេអស់រយៈពេលជាច្រើនឆ្នាំពីដំបូង។ ប្រការ នេះទំនងជាធ្វើឲ្យគេមានលទ្ធភាពអភិវឌ្ឍជំនាញមូលដ្ឋាន ដែលគាំទ្រសង្គម។

ទន្ទឹមនឹងអ្នកថែរក្សា សុខ គុន វាយតម្លៃឥរិយាបថមានប្រយោជន៍ និងស្លូតបូតរបស់គេផ្អែកលើ SDQ ថាមានកម្រិតទាបបន្តិច ហើយម្តាយ និងគ្រូរបស់គេវាយតម្លៃឥរិយាបនេះ ថាមានកម្រិតជិតមធ្យមបើប្រៀបធៀបនឹងក្មេងដទៃទៀតអាយុស្រករគ្នាក៏ដោយ ក៏ជាទូទៅ សុខ គុន រីករាយនឹងជួយអ្នកដទៃ ជាពិសេសនៅពេលគេមានពេលនៅជាមួយមនុស្សដែលគេចូលចិត្ត។ លើសពីនេះ សុខ គុន ថែទាំក្មេងៗនៅពេលពួកគេឈឺចាប់ ឬមិនសប្បាយចិត្ត ហើយគេមានការព្រួយបារម្ភណាស់ ប្រសិនបើគេបង្កគ្រោះថ្នាក់ដល់មនុស្សណាម្នាក់។ ប្រការនេះ បញ្ជាក់ពីការរីកចម្រើននូវឥរិយាបថដែលសង្គមទទួលយក ហើយនឹងការរីកចម្រើនការយល់ដឹងពីការយល់ចិត្តគ្នា។

ជំនាញទាំងនេះ ទំនងជាមានការវិវត្តន៍បំផុតតាមរយៈមណ្ឌលសុខភាពនៅមណ្ឌលអប់រំកែប្រែទី២ ដែល សុខ គុន ធ្លាប់បានរស់នៅការរស់នៅជាប់ជាមួយម្តាយនៅក្នុងប៉ុន្មានឆ្នាំដំបូង។ ការរស់នៅជាប់ជាមួយម្តាយ និងភាពរឹងមាំរបស់ សុខ គុន ជាមួយម្តាយ គឺជាកត្តាការពារមួយ ដែលធ្វើឲ្យ សុខ គុន មានលទ្ធភាព បង្កើតទំនាក់ទំនងរហូតមកទល់ពេលនេះ។ គេបង្ហាញឲ្យឃើញផងដែរ នូវភាពមិនទុកចិត្តសមស្របចំពោះមនុស្សចំឡែក និងភាពប៉ិនប្រសប់យ៉ាងល្អដើម្បីទុកចិត្តមនុស្សថ្មីៗនៅពេលគេចាប់ផ្តើមស្គាល់អ្នកទាំងនោះ។ វាទំនងថាចំណងទាក់ទង រឹងមាំជាមួយម្តាយ ផ្តល់ឱកាសឲ្យគេពុះពារនឹងបទពិសោធន៍ខ្លះ ក្នុងចំណោមបទពិសោធន៍ពន្ធនាគារ ដែលប៉ះទង្គិចផ្លូវចិត្តរបស់គេយ៉ាងច្រើន។

សុខ គុន និយាយអំពីម្តាយគេយ៉ាងងាយស្រួល ហើយប្រកបទៅដោយសមានចិត្ត។ គេនិយាយថាគេនឹកម្តាយ បារម្ភពីម្តាយច្រើនណាស់ ហើយចូលចិត្តទៅសួរសុខទុក្ខគាត់។ រាល់ថ្ងៃ ពេលទំនេរគេទៅលេងនឹងមិត្តភក្តិនៅជនបទ។ ម្តាយរបស់គ្រួសារនេះ រាយ-ការណ៍ថា សុខ គុន នៅតែមានបញ្ហាពេលគេងយប់ ហើយជារឿយៗត្រូវការម្តាយដេកជិត និងថ្នាក់ថ្នមគេ ដែលជាការបញ្ជាក់ពីការនឹករលឹកម្តាយ ហើយនឹងការថ្នាក់ថ្នម ដែលម្តាយអាចផ្តល់ឲ្យគេក្នុងពន្ធនាគារ។

## ផ្ទះកុមារ៖ ការសម្លឹងមើលទៅអនាគត

ដោយមានជំនួយពីអង្គការលីកាដូ សុខ គុន បានចាកចេញពីមណ្ឌលអប់រំកែប្រែទី២ ក្នុងខែមករា ឆ្នាំ ២០១២ ហើយចាប់ពីពេលនោះមកបានមករស់នៅឯផ្ទះកុមារក្នុងខេត្តកណ្តាលដែលបច្ចុប្បន្នផ្ទុកកុមារចំនួន ១៦ នាក់ ដែលមានអាយុចាប់ពី ៦ ឆ្នាំដល់ ១៦ ឆ្នាំ។ ផ្ទះនេះ បានទទួលការឧបត្ថម្ភពីអង្គការម្តាយប្រឆាំងនឹងភាពក្រីក្រ (MAP) ហើយដឹកនាំដោយ Chibodia ដែលជាអង្គការមិនមែនរដ្ឋាភិបាលអាឡឺម៉ង់។ កុមារចូលរៀនសាលារដ្ឋ ហើយមានថ្នាក់រៀនបន្ថែមជាច្រើននៅក្នុងមណ្ឌលនេះ។ ដោយមានជំនួយពីអង្គការលីកាដូ សុខ គុន អាចមានលទ្ធភាពទៅសួរសុខទុក្ខម្តាយរបស់គេនៅពន្ធនាគារយ៉ាងតិចណាស់ ១ ដងក្នុង១ ខែ។

តាមរយៈការវាយតម្លៃរបស់អង្គការ INDIGO សុខ គុន ត្រូវបានគេប្រាប់ឲ្យគូសវាសគម្រោងជីវិតរបស់គេ ទៅអនាគតនៅលើក្រដាសមួយ។ គេបានគូររូបទារកម្នាក់មានមុខគួរឲ្យកំសត់ ហើយនឹងគូររូបភាពមួយមានភាពរីករាយ ដែលពិពណ៌នាអំពីផ្ទះថ្មីរបស់គេ ដោយបញ្ជាក់យ៉ាងច្បាស់ថា គេមានអារម្មណ៍អាចសុខស្រួលនៅផ្ទះថ្មីរបស់គេ ប៉ុន្តែថារឿងអតីតកាលរបស់គេនៅក្នុងពន្ធនាគារ នឹងក្លាយជាបន្ទុកសម្រាប់រូបគេជាដរាប។

នៅពេលបុគ្គលិកពីអង្គការ INDIGO បានជួប សុខ គុន ដំបូង គេជាក្មេងប្រុសម្នាក់មានប្រាជ្ញា ហើយរួសរាយរាក់ទាក់ ដែលបានប្រាស្រ័យទាក់ទងជាមួយនីតិជនបាន យ៉ាងស្រួល។ តាមការវាយតម្លៃ សុខ គុន បានបញ្ជាក់ដោយផ្ទាល់នូវសមត្ថភាពក្នុងការបង្ហាញយ៉ាងច្បាស់ពីបំណងប្រាថ្នារបស់គេ និងសេចក្តីត្រូវការនានា ខណៈដែលរៀបចំព្រំដែនរបស់គេ ឧ៖ ទាក់ទងនឹងប្រធានបទសន្ទនា។


កុមារម្នាក់មកសួរសុខទុក្ខម្តាយរបស់គាត់នៅមណ្ឌលអប់រំកែប្រែទី២ ក្នុងរាជធានីភ្នំពេញ

នៅពេល សុខ គុន មករស់នៅក្នុងផ្ទះកុមារដំបូង គេមានអាការៈភ័យខ្លាច និងស្លន់ស្លោ។ ជួនកាលគេហាក់ដូចជាមានកម្លាំងច្រើនណាស់ ហើយនឹងមានបញ្ហាដេកយប់។ នេះ ត្រូវចំណាយពេលវេលាមួយចំនួន មុនពេលគេសាំទៅនឹងទីតាំងថ្មីប្រចាំថ្ងៃ។ ពីដំបូងគេបង្ហាញឲ្យឃើញពីបញ្ហាឥរិយាបថជាក់ស្តែងផងដែរ ដូចជាការវាយតប់ សកម្មភាពលួច និងឥរិយាបថស្រើបស្រាល។ ទោះជាមានភាពប្រសើរឡើងក៏ដោយ ក៏នៅតែមានការព្រួយបារម្ភធ្ងន់ធ្ងរខ្លះដដែលពីបញ្ហាទាំងនេះ។

ទោះជាចំណងទាក់ទងរឹងមាំជាមួយម្តាយអាចឲ្យ សុខ គុន រីកចម្រើនជំនាញមូលដ្ឋាន ដែលសង្គមទទួលស្គាល់ នៅពេលរស់នៅក្នុងពន្ធនាគារក៏ដោយ ក៏គេនៅតែតស៊ូជាមួយអន្តរកម្មសង្គម ប្រចាំថ្ងៃ ហើយនឹងបង្ហាញពីឥរិយាបថមិនប្រក្រតី ដែលជាក់ស្តែងកើតចេញពីបទពិសោធន៍ពន្ធនាគាររបស់គេ។

សម្ព័ន្ធភាពរឹងប៉ឹងរបស់ សុខ គុន ចំពោះម្តាយរបស់គេទំនងជាបានធ្វើឲ្យគេ មានលទ្ធភាពបង្កើនទំនុកចិត្ត និងជំនាញសមានចិត្ត ដែលធ្វើឲ្យគេអាចជឿទុកចិត្ត និងអាស្រ័យលើមនុស្សដទៃទៀត ប៉ុន្តែជំនាញសង្គមផ្ទៃក្រៅរបស់ សុខ គុន ពុំមានការរីកចម្រើនដូចកុមារដទៃទៀត ដែលមានអាយុស្រករគ្នា។ ប្រការនេះអាចបន្តបង្កបញ្ហាសម្រាប់រូបគេទៅអនាគត ជាពិសេសនៅពេលបង្កើតមិត្តភក្តិ និងនៅពេលចុះសម្រុងទៅនឹងសាលា។

ដោយសារបរិយាកាសស្ថិរភាព និងមានរចនាសម្ព័ន្ធត្រឹមត្រូវបែបអភិរក្សនៅផ្ទះកុមាររបស់អង្គការ Chibodia នោះ សុខ គុន បានព្យាយាមដើម្បីដោះស្រាយនឹងបញ្ហាប្រឈមជាច្រើន ហើយនឹងបានធ្វើឲ្យមានភាពជឿនលឿនផ្នែកអប់រំ និងសង្គមយ៉ាងច្រើន។ ការវិលត្រឡប់ទៅរកភាពប្រក្រតីឡើងវិញរបស់គេ គឺជាចំណុចខ្លាំងមហិមារបស់គេ ហើយគេបានបង្កើនសមត្ថភាព ដើម្បីធ្វើនិយតកម្មអារម្មណ៍ និងត្រួតត្រាកំហឹងរបស់គេ។ បុគ្គលិកអង្គការ Chibodia មានសេចក្តីរីករាយ ចំពោះភាពជឿនលឿនរបស់គេហើយសង្ឃឹមថាគេអាចរួចចាកផុតពីបទពិសោធន៍ពន្ធនាគារ ដែលប៉ះទង្គិចផ្លូវចិត្តរបស់គេ។

សុខ គុន អាចទទួលបានការគាំទ្រពីអង្គការ Chibodia យ៉ាងតិចណាស់រហូតដល់គេបញ្ចប់ការអប់រំសាលារដ្ឋ។ នៅពេលណាម្តាយរបស់គេ ត្រូវបានដោះលែងពីពន្ធនាគារ សុខ គុន អាចរស់នៅជាមួយម្តាយគេជាថ្មី ប្រសិនបើគេមានចិត្តចង់ ហើយប្រសិនបើម្តាយគេអាចមានលទ្ធភាពខាងហិរញ្ញវត្ថុ ដើម្បីទំនុកបម្រុងរូបគេជាថ្មីក្នុងបរិយាកាសស្ថិរភាព។

# សេចក្តីសន្និដ្ឋាន

**រឿងរ៉ាវរបស់ សុខ គុន គូសបញ្ជាក់ពីសារៈសំខាន់ក្នុងការដាក់វិធានការពិសេសនានាឲ្យមានដំណើរការ នៅពេលក្មេងៗត្រូវបានដាក់នៅក្នុងពន្ធនាគារជាមួយម្តាយរបស់អ្នកទាំងនោះ។ ផលប៉ះពាល់ពីបទពិសោធន៍ពន្ធនាគារជាអវិជ្ជមានរបស់គេផ្តល់នូវការយល់ដឹងពីអ្វីអាចកើតឡើងនៅពេលគ្មានវិធានការសមស្រប។**

ទន្ទឹមនឹងវិធានការមិនឃុំខ្លួនជាជម្រើសល្អ សម្រាប់ស្ត្រីមានគភ៌ និងស្ត្រីមានកូនក្នុងបន្ទុកនោះ នៅក្នុងករណីរបស់ សុខ គុន ជម្រើសនេះ ជាជម្រើសមួយដែលមិនទំនង ដោយសារចរិតលក្ខណៈនៃបទល្មើសដែលត្រូវបានចោទលើម្តាយ។ វិធានការជម្រើសផ្សេងសម្រាប់ការថែទាំគេ នឹងមានការលំបាកផងដែរ ដោយសារគ្មានភាពជាអាណាព្យាបាលជាជម្រើសផ្សេងសមរម្យ។

សុខ គុន បានចាកចេញពីពន្ធនាគារមិនយូរប៉ុន្មាន បន្ទាប់ពីបានអនុម័តច្បាប់ស្តីពីពន្ធនាគារក្នុងខែធ្នូ ឆ្នាំ២០១១ ដែលបន្ថយអាយុកុមារអនុញ្ញាតឲ្យស្នាក់នៅក្នុងពន្ធនាគារពីអាយុ ៦ ឆ្នាំមកនៅក្រោម ៣ ឆ្នាំ។ តាមច្បាប់គេគួរតែត្រូវបានចាកចេញពីពន្ធនាគារ ១០ ខែមុនពេល ដែលគេបានចេញ។ ប៉ុន្តែបើប្រៀបធៀបនឹងក្មេងដទៃទៀតនៅក្នុងពន្ធនាគារ ការកំណត់ពេល និងកាលៈទេសៈនៃការចាកចេញពីពន្ធនាគាររបស់គេមានលក្ខណៈសមហេតុផលនៅក្នុងបរិបទកម្ពុជា។

អ្វីដែលគូសបញ្ជាក់តាមរឿងរ៉ាវរបស់ សុខ គុន គឺជាសារៈសំខាន់ក្នុងការដាក់វិធានការពិសេសនានាឲ្យមានដំណើរការនៅពេលក្មេងៗត្រូវបានដាក់នៅក្នុងពន្ធនាគារ ជាមួយម្តាយរបស់អ្នកទាំងនោះ។ ផលប៉ះពាល់ពីបទពិសោធន៍ពន្ធនាគារជាអវិជ្ជមានរបស់គេ ផ្តល់នូវការយល់ដឹងពីអ្វីអាចកើតឡើងនៅពេលគ្មានវិធានការសមស្រប។

គោលការណ៍គន្លឹះទី១ ដែលណែនាំអំពីការគ្រប់គ្រងក្មេងៗក្នុងពន្ធនាគារជាមួយម្តាយរបស់ពួកគេគឺមានន័យថា ក្មេងៗទាំងនេះមិនគួរត្រូវបានគេចាត់ទុកជាអ្នកទោសឡើយ[១៣] ។ គោលការណ៍គន្លឹះទី២ គឺមានន័យថា បរិយាកាសរបស់ក្មេងក្នុងពន្ធនាគារ គួរតែនៅជិតបរិយាកាសរបស់ក្មេង ដែលនៅក្រៅពន្ធនាគារ[១៤] តាមដែលអាចធ្វើបាន ។

[១៣] វិធាន ៤៩ នៃវិធានក្រុងបាងកក។
[១៤] វិធាន ៥១(២) នៃវិធានក្រុងបាងកក។

ទន្ទឹមនឹងបទពិសោធន៍អវិជ្ជមាន ជាផលវិបាកពីជីវិតពន្ធនាគារ ដែលមិនអាចចៀសផុតសម្រាប់កុមារនោះ វាទំនងថាប្រសិនបើគោលការណ៍ទាំងនេះ ត្រូវបានគេអនុវត្តតាមផលប៉ះពាល់យូរអង្វែងទៅលើ សុខ គុន នឹងកាត់បន្ថយ។



កុមារម្នាក់រស់នៅក្នុងប៉ុស្តិ៍សុខភាព ក្នុងមណ្ឌលអប់រំកែប្រែ ទី២ ចូលក្នុងបន្ទប់សម្រាប់អ្នកទោស ដែលមានជម្ងឺ

ប្រសិនបើអាជ្ញាធរពន្ធនាគារ នៅមណ្ឌលអប់រំកែប្រែទី២ បានអនុវត្តគោលការណ៍ទាំងនេះ ប្រហែលជា សុខ គុន មិនត្រូវបានគេដាក់ឲ្យស្ថិតនៅក្នុងចំណោមជនជាប់ឃុំទូទៅក្នុងពន្ធនាគារ ១ ក្នុងចំណោមពន្ធនាគារទាំងឡាយរបស់ប្រទេសកម្ពុជា ដែលមានបញ្ហា និងចង្អៀតណែនបំផុតនោះទេ។ អាជ្ញាធរពន្ធនាគារគួរតែការពារគេឲ្យផុតពីទិដ្ឋភាពនៃជីវិតពន្ធនាគារ ដែលអាក្រក់បំផុត រាប់ទាំងអំពើហិង្សា និងការលេងល្បែងស៊ីសងដែល សុខ គុន បានពិពណ៌នា។ ប្រហែលជាសំខាន់បំផុតនោះ សុខ គុន មិនគួរណាឲ្យឃើញអត្តឃាតកម្ម នៅក្នុងពន្ធនាគារ នោះឡើយ។

ការសម្រេចផ្ទេរស្ត្រីដែលមានកូនទាំងអស់ និងស្ត្រីមានគ៌ភ៌មួយចំនួនឲ្យទៅរស់នៅក្នុង ប៉ុស្តិ៍សុខភាពរបស់ពន្ធនាគារ គឺជាការរៀបផែនការមិនទាន់បានល្អផងដែរ។ វាជាអកុសលសម្រាប់ សុខ គុន និងម្តាយរបស់គេដែលអ្នកទាំង ២ នាក់ មិនអាចទទួលបានផលប្រយោជន៍ពីអគារស្នាក់នៅថ្មីមួយចំនួន ក្នុងមណ្ឌលអប់រំកែប្រែទី២ ដែលត្រូវបានរៀបចំពិសេសសម្រាប់ស្ត្រីដែលមានកូន និងស្ត្រីមានគភ៌។

មានផលប្រយោជន៍មិនអាចប្រកែកបានក្នុងការអនុញ្ញាតឲ្យកុមារកម្ពុជារស់នៅជាមួយម្តាយរបស់ពួកគេក្នុងពន្ធនាគារ ជាពិសេសដោយពិនិត្យទៅលើប្រព័ន្ធសុខុមាលភាពកុមារកម្ពុជា ដែលបានរីកចម្រើនមិនគ្រប់គ្រាន់ និងបទដ្ឋានរស់នៅយ៉ាងលំបាករបស់ប្រជាពលរដ្ឋកម្ពុជាភាគច្រើន។ ផលប្រយោជន៍ទាំងនេះ រាប់ទាំងការកាត់បន្ថយឱកាសបោះបង់ចោលកុមារ ឬឱកាសបញ្ជូនកុមារទៅកាន់មណ្ឌលស្នាក់នៅមិនគ្រប់គ្រាន់។ ជាការវិវឌ្ឍន៍ កុមារអាចទទួលផល ប្រយោជន៍ពីការបន្តចិញ្ចឹមបីបាច់ពីទំនាក់ទំនងរវាងកូន និងម្តាយ។ ទោះបីយ៉ាងណាក៏ដោយ សំណួរថាតើផលប្រយោជន៍អាចមានទម្ងន់ច្រើនជាងគុណវិបត្តិ ឬយ៉ាងណានោះអាចត្រូវកំណត់ បានតាមរយៈវិធីសាស្ត្រតាមករណីនីមួយៗដោយពិស្តារ។

តាមបទពិសោធន៍របស់ សុខ គុន វាទំនងថាឱកាសវិជ្ជមានដើម្បីទំនាក់ទំនង ជាមួយម្តាយ របស់គេ អាចមានទម្ងន់ ច្រើនជាងបទពិសោធន៍អវិជ្ជមានមួយចំនួន ប៉ុន្តែនៅតែមានការលំបាក ក្នុងការព្យាករណ៍ពីផលប៉ះពាល់ខាងចិត្តសាស្ត្រ ជាសក្តានុពលរយៈពេលយូរទៅលើ សុខ គុន។ វាជាការព្រួយបារម្ភយ៉ាងខ្លាំងថា សុខ គុន នៅតែទទួលរងសុបិនអាក្រក់ និងស្រមោលអតីតកាល លួចអាហារ និងវត្ថុកំប៉ិក កំប៉ុកដទៃទៀត ព្រមទាំងបង្ហាញឲ្យឃើញនូវអាការៈតក់ស្លុត និងការភ័យ ខ្លាចខុសប្រក្រតីពីការរងរបួសរាងកាយ។



កុមារ និងស្ត្រីមានផ្ទៃពោះម្នាក់ ទទួលបានអំណោយពីអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងមណ្ឌលអប់រំកែប្រែទី២

ជាអកុសលបុគ្គលិកពន្ធនាគារនៅកម្ពុជា ខ្វះការយល់ដឹង និងការបណ្តុះបណ្តាល ដែល ត្រូវការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ស្ត្រីមានគភ៌ និងស្ត្រីមានកូនរស់នៅក្នុងពន្ធនាគារ ហើយក៏គ្មានឱកាសសម្រាប់អ្នកឯកទេស ដើម្បីឃ្លាំមើលការចម្រើនលូតលាស់របស់កុមារឡើយ។ ប្រសិនបើមានការបណ្តុះបណ្តាល និងមានឱកាស បែបនេះបញ្ហាឥរិយាបថមួយចំនួនរបស់ សុខ គុន អាចត្រូវបានរកឃើញ ហើយអាចនឹងដោះស្រាយបាននៅដំណាក់កាលដំបូង។

ការព្រួយបារម្ភជារួមសម្រាប់កុមារ ដែលបានចម្រើនវ័យក្នុងពន្ធនាគារនោះ គឺថានៅទីបំផុត ពួកគេអាចប្រព្រឹត្តបទល្មើសដោយផ្ទាល់ ហើយក៏ត្រូវបញ្ជូនពួកគេមកកាន់ពន្ធនាគារវិញ នៅពេលពួក គេគ្រប់អាយុទទួលខុសត្រូវខាងព្រហ្មទណ្ឌ[១៥] ។ ក្មេងៗដូចជា សុខ គុន មិនគ្រាន់តែអាច អភិវឌ្ឍឥរិយាបទខុសប្រក្រតី នៅពេលរស់នៅក្នុងពន្ធនាគារប៉ុណ្ណោះទេ ប៉ុន្តែអ្នកទាំងនោះថែមទាំងអាចចាត់ទុកពន្ធនាគារ និងគុណតម្លៃដែលពួកគេទទួលបាន ពីពន្ធនាគារ ថាជារឿងធម្មតាណាស់ទៅវិញ។ ទំនងបំផុតនោះពួកគេក៏នឹងជក់ជាប់នូវស្លាកស្នាមអាក្រក់ពីជីវិតក្នុងពន្ធនាគារផងដែរ ដែលជាលទ្ធផលពួកគេត្រូវបានសង្គមរុញចេញ។

ទន្ទឹមនឹងសេចក្តីសង្ឃឹមរបស់ សុខ គុន មានលក្ខណៈល្អ ដោយសារគេមានទំនាក់ទំនងជិតដិតជាមួយម្តាយគេ និងបរិយាកាសដែលស្និទ្ធភាព និងអភិរក្សនោះ និន្នាការបច្ចុប្បន្នរបស់គេ ទាក់ទងនឹងសកម្មភាពល្មួច ហើយនឹងការបំពារបំពានខាងរាងកាយរបស់គេ នៅតែជាបញ្ហាកង្វល់ក្នុងសភាពបែបនេះនៅឡើយ។

សុខ គុន មានភ័ព្វសំណាងទទួលបានជំនួយ និងការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល នៅប្រទេសកម្ពុជាជាអ្នកទទួលខុសត្រូវដើម្បីធានាឲ្យគេបានចេញពីពន្ធនាគារ ហើយដាក់រូបគេឲ្យ ស្ថិតក្រោមភាពអាណាព្យាបាលសមស្រប និងមានសុវត្ថិភាព។ ទោះបីយ៉ាងណាក៏ដោយ ការទទួលខុសត្រូវនេះ គឺជាបន្ទុករបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ក្នុងករណីចាំបាច់ និងសមស្រប។ ក្នុងបរិបទនេះក្រសួងសង្គមកិច្ច មិនគ្រាន់តែត្រូវការចំណេះដឹងនិងធនធានប៉ុណ្ណោះទេ ប៉ុន្តែថែម ទាំងត្រូវការឆន្ទៈនយោបាយផងដែរ ដើម្បីអនុវត្តតួនាទីរបស់ស្ថាប័នឲ្យបានពេញលេញ និងប្រកបដោយការទទួលខុសត្រូវ។

# អនុសាសន៍នាំទឡ្យ

## ►►► ការវាយតម្លៃជាលក្ខណៈបុគ្គល និងទូលំទូលាយ

អគ្គនាយកដ្ឋានពន្ធនាគារ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរតែធ្វើការវាយតម្លៃពីស្ថានភាពរបស់កុមារម្នាក់ៗ ដើម្បីសម្រេចថា តើវាមានភាពប្រសើរ ឬទេ ប្រសិនបើបំបែកកុមារចេញពីម្តាយរបស់ពួកគេក្នុងពន្ធនាគារ ឬសម្រេចថាកុមារគួររស់នៅជាមួយម្តាយរបស់គេក្នុងពន្ធនាគារ ឬយ៉ាងណា។ ការវាយតម្លៃនេះ គួរតែត្រូវធ្វើឡើង (ព្រោះវាជាបទដ្ឋាននៅក្នុងប្រទេសផ្សេងៗជាច្រើនលើពិភពលោក) មុនពេលកុមារចូលទៅរស់នៅក្នុងពន្ធនាគារ។ ការវាយតម្លៃដូចគ្នានេះ ត្រូវតែបានធ្វើឡើង នៅពេលក្មេងចាប់កំណើត ខណៈដែលម្តាយត្រូវបានឃុំខ្លួន ដើម្បីសម្រេច ថាតើនឹងរយៈពេលយូរប៉ុណ្ណា ទារកនោះគួរស្នាក់នៅក្នុងពន្ធនាគារ (ឬថាតើទារកនោះ គួរស្នាក់នៅក្នុងពន្ធនាគារ ឬយ៉ាងណា)។ ការវាយតម្លៃនេះ គួរប្រកាន់យកវិធីសាស្ត្ររួម ដោយពិនិត្យទៅលើផលប្រយោជន៍ និងសិទ្ធិរបស់កុមារដើម្បីចម្រើនលូតលាស់[១៦] ព្រមទាំងផលប្រយោជន៍ពីការបន្តទំនាក់ទំនងរវាងកូន និងម្តាយប្រសិនបើកុមារនោះស្នាក់នៅជាមួយម្តាយក្នុងពន្ធនាគារ។ ការវាយតម្លៃនេះ គួរតែពិនិត្យផងដែរ ទៅលើប្រព័ន្ធសុខុមាលភាពកុមារកម្ពុជា ដែលត្រូវបានរីកលូតលាស់មិនគ្រប់គ្រាន់ ព្រមទាំងហានិភ័យនៃការបោះបង់ចោលកុមារ និងមណ្ឌលស្នាក់នៅមិនគ្រប់គ្រាន់។

## ►►► គោលការណ៍ណែនាំពិស្តារ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការសហការជាមួយអគ្គនាយកដ្ឋានពន្ធនាគារគួរតែចេញសេចក្តីណែនាំទាំងឡាយ ស្តីពីរបៀបចាត់ការ និងពង្រឹងប្រព័ន្ធផ្ទេរខាងក្រៅ (បញ្ជូន) និងការដាក់កុមារអាយុលើសពី ៣ ឆ្នាំឡើងទៅដែលនៅតែកំពុងរស់នៅក្នុងពន្ធនាគារ ឲ្យស្ថិតនៅក្រោមភាពអាណាព្យាបាល។ នេះជាការចាំបាច់ដើម្បីធានាថា ការបំបែកកុមារពីម្តាយត្រូវតែបានគ្រប់គ្រង និងអនុវត្តតាមរបៀបសុភវិនិច្ឆ័យ និងពេលវេលាសមស្រប ហើយតែក្នុងករណី ដែលមានការរៀបចំថែទាំជំនួសសមស្របត្រូវបានដាក់ឲ្យដំណើរការ។

គោលនយោបាយដែលមានស្រាប់តាំងពីខែមេសា ឆ្នាំ២០០៦ មកស្តីពីការថែទាំជំនួសសម្រាប់កុមារនៅប្រទេសកម្ពុជា ផ្តល់ក្របខណ្ឌមួយយ៉ាងល្អដែលចែងថាជម្រើសទី១ គឺត្រូវដាក់កុមារឲ្យស្ថិតក្រោមភាពអាណាព្យាបាលរបស់សាច់ញាតិ បន្ទាប់មកការថែរក្សារបស់

[១៥] អាយុ ១៤ឆ្នាំ គឺជាអាយុទទួលខុសត្រូវខាងព្រហ្មទណ្ឌនៅកម្ពុជា។
[១៦] មាត្រា ៥ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

ឪពុកម្ដាយចិញ្ចឹម ហើយបន្ទាប់មកទៀត ដាក់ក្នុងផ្ទះកុមារ។

## ►►► ការដោះលែងបណ្ដោះអាសន្នក្រោមការត្រួតពិនិត្យ និងទោសមិនឃុំខ្លួន

ស្របតាមវិធានសហប្រជាជាតិសម្រាប់គ្រប់គ្រងអ្នកទោសជាស្ត្រី និងវិធានការមិនឃុំខ្លួន សម្រាប់ជនល្មើសជាស្ត្រី (វិធានក្រុងបាងកក) អាជ្ញាធរតុលាការគួរតែកំណត់ស្ត្រី ដែលមានកូនក្នុងបន្ទុក (នៅក្នុង ឬនៅក្រៅពន្ធនាគារ) ដែលជាបេក្ខជន សម្រាប់ដោះលែងបណ្ដោះអាសន្នក្រោមការត្រួតពិនិត្យ និង/ឬទោសមិនឃុំខ្លួន។ អាជ្ញាធរគួរតែធ្វើការតស៊ូមតិដល់ចៅក្រម និងព្រះរាជអាជ្ញាដើម្បីរក្សាទុកក្រុមគ្រួសារ ក្នុងករណីដែលអាចធ្វើបាន ដើម្បីមិនត្រូវបង្ខំក្មេងឲ្យទៅរស់នៅក្នុងពន្ធនាគារជាមួយម្ដាយរបស់គេ ឬក៏ទុកពួកគេចោលនៅខាងក្រៅឡើយ។

អាជ្ញាធរគួរតែសង្កត់ធ្ងន់ផងដែរទៅលើស្ត្រី ដែលទទួលឲ្យចូលមករស់នៅក្នុងពន្ធនាគារ មានគភ៌។ ការដោះលែងបណ្ដោះអាសន្នក្រោមការត្រួតពិនិត្យ និង/ឬទោសមិនឃុំខ្លួនសម្រាប់ស្ត្រីមានគភ៌ អាចកាត់បន្ថយចំនួនកុមារ រស់នៅជាមួយម្ដាយរបស់ពួកគេក្នុងពន្ធនាគារ។

## ►►► ការបណ្ដុះបណ្ដាល និងកម្មវិធីលើកកម្ពស់ការយល់ដឹង

បុគ្គលិកពន្ធនាគារគួរតែទទួលការបណ្ដុះបណ្ដាល ស្ដីពីការចម្រើនលូតលាស់របស់កុមារ ហើយនឹងសេចក្ដីត្រូវការថែទាំសុខភាពរបស់កូន និងម្ដាយមានគភ៌ ដើម្បីឲ្យពួកគេអាចឆ្លើយតបសមស្រប នៅពេលត្រូវការ និងនៅពេលមានភាពអាសន្ន។ គួរតែចាត់ឲ្យមានអ្នកឯកទេស ដើម្បីឃ្លាំមើលការចម្រើនលូតលាស់របស់កុមារ ដើម្បីអាចកំណត់បញ្ហានានានៅដំណាក់កាលដំបូង។

## ►►► បន្ថែមធនធាន

អគ្គនាយកដ្ឋានពន្ធនាគារ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវចាត់ឲ្យមានធនធានបន្ថែម ដើម្បីស្វែងយល់ និងលើកស្ទួយសិទ្ធិកុមារ និងស្ត្រីជាម្ដាយក្នុងពន្ធនាគារ ពិនិត្យឡើងវិញនូវដំណើរការធ្វើសេចក្ដីសម្រេច ដែលនាំឲ្យកុមារតាមម្ដាយរបស់គេទៅពន្ធនាគារ និងវាយតម្លៃផលប៉ះពាល់ពីការឃុំខ្លួនទៅលើកុមារ។

## ►►► ការចែករំលែកព័ត៌មាន និងការណែនាំ

អគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល និងក្រសួងយុត្តិធម៌ គួរតែបង្កើន និងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីចែករំលែកព័ត៌មាន និងណែនាំមន្ត្រីទាំងឡាយអំពីសេចក្ដីត្រូវការរបស់ស្ត្រីមានគភ៌ និងកុមាររស់នៅជាមួយម្ដាយរបស់ពួកគេក្នុងពន្ធនាគារកម្ពុជា។

## ►►► បង្កើនថវិកា

អគ្គនាយកដ្ឋានពន្ធនាគារគួរតែបង្កើនថវិកា និងធនធានសម្រាប់ស្ត្រីមានគភ៌ និងស្ត្រីកំពុងបំបៅដោះកូន ព្រមទាំងកុមាររស់នៅជាមួយម្ដាយរបស់ពួកគេក្នុងពន្ធនាគារ។ ក្រុមមនុស្សទាំង នេះមានលក្ខខណ្ឌតម្រូវពិសេស ដែលគួរតែគិតគូរអំពីថវិកា។